ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ : ០៧២៨៣សក.អល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការងារជួសជុលផ្លូវដោយក្រាលកៅស៊ូ DBST ប្រវែង ៥.៥៣៣ម ទទឹង ៦ម ស្ថាបនាប្រព័ន្ធលូបង្ហូរទឹក ប្រវែង ៤.៣១៤ម និងរីហ្គា ចំនួន ១៧៤កន្លែង លើផ្លូវខេត្តលេខ ១១០ ចន្លោះគ.ម២០+៥០០ ដល់គ.ម៣៥+០០០ ស្ថិតក្នុងស្រុកកៀនស្វាយ និងស្រុកស្អាង ខេត្តកណ្តាល

បានពិនិត្យត្រឹមត្រូវ
អង្គភាពលទ្ធកម្មសាធារណៈ

ក្រសួងសាធារណការ និងដឹកជញ្ជូន សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការធ្វើ ការងារជួសជុលផ្លូវដោយក្រាលកៅស៊ូ DBST ប្រវែង ៥.៥៣៣ម ទទឹង ៦ម ស្ថាបនាប្រព័ន្ធលូបង្ហូរទឹក ប្រវែង ៤.៣១៤ម និងរីហ្គា ចំនួន ១៧៤កន្លែង លើផ្លូវខេត្តលេខ ១១០ ចន្លោះគ.ម២០+៥០០ ដល់គ.ម៣៥+០០០ ស្ថិតក្នុងស្រុកកៀនស្វាយ និងស្រុកស្អាង ខេត្តកណ្តាល ។

ក្រសួងសាធារណការ និងដឹកជញ្ជូន បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃ មានដាក់លក់នៅ អង្គភាពលទ្ធកម្មនៃក្រសួងសាធារណការ និងដឹកជញ្ជូន ដែលមានអាសយដ្ឋាន អគារមហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០១៦ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ 011 835 857 ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦ វេលាម៉ោង ៩:០០ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅ អង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ៩:០០ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ភ្នំពេញ,ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥

ជ. រដ្ឋមន្ត្រី
រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម
ក្រសួងសាធារណការ និងដឹកជញ្ជូន

ឈួច ចាន់កុសល

ចម្លងជូន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
*(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)*
- អង្គភាពប្រឆាំងអំពើពុករលួយ (ACU)
- ឯកសារ-កាលប្បវត្តិ



មហាវិថី ព្រះនរោត្តម, ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥) ២៣ ៤២៦ ៦៤០, (៨៥៥) ២៣ ៤២៧ ៨៦២